35/

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៩

ចុះថ្ងៃទី១៩ ០៣ ២០០៤

សាលដីកា

លេខ: ៧០

ចុះថ្ងៃទី២៩ ១២ ២០០៤

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ជីវ កេង ចៅក្រម

៤ - លោក ប៉ែន សាវឿន ចៅក្រមរបាយការណ៍

៥ - លោក ម៉ុង មុនីចរិយា ចៅក្រម

លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនលៀង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១០៨ "ឃ" ចុះថ្ងៃទី២១ ០៣ ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ២៩ ចុះថ្ងៃទី១៩ ០៣ ២០០៤របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ ចាក់ ផាត "ចុងបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ៤៧ ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិអង្គរជ័យកណ្តាល ឃុំ ពោធិ៍ទ្រាល ស្រុក គងពិសី ខេត្តកំពង់ស្ពឺ មុខរបរនគរបាល ទីលំនៅក្រុមទី១២ មណ្ឌល២ សង្កាត់៣ ខណ្ឌ មិត្តភាព ក្រុងព្រះសីហនុ ប្រពន្ធឈ្មោះខៀវ លាទៀន មានកូន០៣នាក់ ឪពុកឈ្មោះ ចាក់ ពិន "ស" ម្តាយឈ្មោះ ណប់ចេង "ស" ។ ឃុំខ្លួននៅពន្ធនាគារព្រៃស ។

- ត្រូវចោទពីបទៈមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅសង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៧ ៤ ១៩៩៤ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- មេធាវី លោក ខៀវ សុផល

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ "ម្ចាស់បណ្តឹងសាទុក្ខ"

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ពុធ អ៊ី ភេទ ប្រុស អាយុ ៥៣ ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅស្នាក់នៅភូមិ ស្រែអំបិល ឃុំ-ស្រុក ស្រែអំបិល ខេត្ត កោះកុង ។

- តាមរបាយការណ៍លេខ៩៧នរបក ស្តីពីករណីឃាតកម្មសម្លាប់មនុស្សចុះថ្ងៃទី១៨ ៤ ១៩៩៤ របស់

......២ ....

ស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ ដែលបញ្ជាក់ថា: កាលពីថ្ងៃទី១១ ៤ ១៩៩៤ វេលាម៉ោង១០ ២៥ នាទី នៅឃុំលេខ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានករណីបាញ់បោកលើមនុស្សត្រូវរបួស យ៉ាងធ្ងន់ធ្ងរនិងស្លាប់នៅមន្ទីរពេទ្យ ក្រោយពេលដួលសន្ត្រោះបាន៤ម៉ោង ។ រឿងហេតុនេះគឺបង្ក ឡើង ដោយឈ្មោះហាក់ ផាត ដែលបានសួរសំឡុតទៅលើចក់ដើងទឹកឲនាក់ ។ លុះក្រោយមកក៏មានការផ្ទុះអាវុធ ហើយត្រូវចំឈ្មោះពៀប នឿន បញ្ជូនដល់មន្ទីរពេទ្យក៏ស្លាប់ទៅ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុថា ចោទប្រកាន់លើឈ្មោះ ហាក់ ផាត ពីបទៈធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីថ្ងៃទី១១ ៤ ១៩៩៤ បទល្មើសដែលមានចែងតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥៧ ចុះថ្ងៃទី០៤ ០៧ ១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - ផ្តន្ទាទោស ហាក់ ផាត ភេទ ប្រុស អាយុ ៣៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ "ដប់ពីរឆ្នាំ" គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីថ្ងៃទី១១ ៤ ១៩៩៤ ។

២ - អោយឈ្មោះហាក់ ផាត សងសំណងនិងជំងឺចិត្តអោយទៅលោក ពុធ អី ជាដើមបណ្តឹងរដ្ឋប្បវេណី ជាប្រាក់ចំនួន២០.០០០.០០០រ០០ "ម្ភៃលានរៀល" សំណើលើសពីនេះត្រូវបដិសេធចោល ។

ករណីទណ្ឌិតខាងលើ គ្មានប្រាក់សងធនទណ្ឌគ្រប់ទេ ត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៣ - វត្ថុតាងមានម៉ូតូម៉ាកសាន់យ៉ាន់ ពណ៌ខ្មៅស៊ុកមួយគ្រឿង ត្រូវប្រគល់ឱ្យជនជាប់ចោទឈ្មោះ ហាក់ ផាត វិញក្រោយពេលអនុវត្តសំណងគ្រប់ចំនួន ។

បទល្មើសនិងការផ្តន្ទាទោសខាងលើ មានចែងនិងផ្តន្ទាទោសតាមមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

- សាលក្រមនេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៦ចុះថ្ងៃទី២៤ ១០ ២០០០ របស់មេធាវីលោកខៀវ សុផល ការពារអោយជនជាប់ចោទឈ្មោះ ហាក់ ផាត តវ៉ាមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៥៧ ចុះថ្ងៃទី ០៤ ០៧ ១៩៩៤ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: ការប្រយមមុខគ្នានេះ គឺជាការបាញ់ឆ្លាទៅវិញទៅមក ហើយជនរងគ្រោះត្រូវគ្រាប់ចំនួន០១គ្រាប់ ជាប់ឆ្អឹងជំនី ដែលផ្ទុយពីការដោះសាររបស់ជនជាប់ចោទ បានបាញ់តែមួយគ្រាប់ប៉ុណ្ណោះ ដើម្បីរាំងទៀត បើពុំដូច្នេះទេ ជនជាប់ចោទមិនរត់គេចខ្លួនឡើយ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០៨ "យ" ចុះថ្ងៃទី២៦ ០៣ ២០០៣ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៤ ១០ ២០០២ របស់លោកមេធាវីខៀវ សុផល ការពារឱ្យជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៧ ចុះថ្ងៃទី០៤ ៧ ១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការដដែល ដោយគ្រាន់តែសំរេចកែប្រែរយៈពេលនៃការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះហាក់ ផាត ក្នុងចំណុចទី១ "មួយ"នៃសេចក្តីសំរេចពី១២"ដប់ពីរ"ឆ្នាំ មក ៦ "ប្រាំមួយឆ្នាំ"វិញ ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៩ ០៣ ២០០៣ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ - ០៣ - ២០០៣ កំបាំងមុខគូក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី២២ ០៥ ២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១០៨ "ឃ"ចុះថ្ងៃទី២៦ ០៣ ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃការផ្តន្ទាទោស ។

- បានឃើញសារណាក្នុងបណ្តឹងសាទុក្ខលេខ១៣២ ចុះថ្ងៃទី១០ ៦ ២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ .

- បានឃើញសារណាតបចុះថ្ងៃទី០៩ ០៧ ២០០៤ របស់ឈ្មោះ ហាក់ ផាត .

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការកំពូលថា:មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ហាក់ ផាត ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្រុងព្រះសីហនុកាលពីថ្ងៃ ១៦ ០៤ ១៩៩៤ប្រាកដមែន សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ១០៨ "ឃ"ចុះថ្ងៃទី២៦ ០៣ ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ក្រឡាបញ្ជីអានសារណាបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍.

- បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ ហាក់ ផាត ឆ្លើយអះអាងនាពេលសវនាការថា: រឿងហេតុទាំងអស់ ខ្ញុំពុំបានដឹងអ្វីទេ ហើយការបាញ់តបតនោះ ខ្ញុំបាទបាញ់ឡើងទៅលើមួយគ្រាប់មែន ។ ការចាប់ខ្លួនពីនគរបាលវិញនោះ ខ្ញុំបាទពុំបានឃើញនគរបាលក្រុងព្រះសីហនុអានសាលក្រមកំបាំងមុខអោយខ្ញុំស្តាប់ទេឡើយ ហើយក៏ពុំបានប្រាប់ពីសាលក្រមកាត់ទោសខ្ញុំបាទដែរ ។ ពេលចាប់ខ្លួនខ្ញុំនោះ មិនដឹងរឿងអ្វីទេ ហើយក៏ពុំឃើញមានអ្នកណាសួរនាំដែរ រូបខ្ញុំបាទស្លូតជានិច្ច លុះក្រោយមកខ្ញុំបាទបានពឹងមេធាវីតាមរយៈប្រពន្ធខ្ញុំ ទើបប្តឹងឧទ្ធរណ៍ តាមលិខិតប្រគល់សិទ្ធិជូនមេធាវីក្នុងការតវ៉ានោះ ។

សូមតុលាការកំពូលមេត្តាកាត់ក្តីរកយុត្តិធម៌ឱ្យខ្ញុំបាទផង ។

- បានស្តាប់មេធាវីលោកខៀវ សុផល ការពារឱ្យជនជាប់ចោទឡើងសន្និដ្ឋាននាពេលសវនាការថា: រឿងហេតុកាត់ក្តីថ្ងៃនេះ តុលាការកំពូលជំនុំជំរះតែលើបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដូច្នេះខ្ញុំបាទសូមទាញរកហេតុផលបន្តិចពីការប្រព្រឹត្តបាញ់តបតគ្នានោះ ។ ដំបូងក្នុងចំណោមផឹកស៊ី មានគ្នាឯងម្នាក់ទៅទិញគ្រឿងក្លែមបន្ថែម ជួបប្រទះក្រុមចោរប្រដាប់អាវុធ

ដោយប្រែកត់ទាមករឿង ក៏បាញ់ប្រាវិញ ឯអ្នកទិញលាចក៏រួមរត់មកប្រាប់ ក៏នាំគ្នារត់ផ្លោះរបង គេចពីការបាញ់នោះ ចំណែកឯឈ្មោះ ហាក់ ផាត ជាកូនក្តីខ្ញុំនេះបានបាញ់ទៅលើមួយគ្រាប់ជាការ តបតប៉ុណ្ណោះ មិនអាចសន្និដ្ឋានថា កូនក្តីខ្ញុំបាញ់នេះត្រូវជនណាទេឡើយ ។ ឯការផ្ទេរសិទ្ធិរបស់កូនក្តីពីង មេធាវី គឺរូបខ្ញុំបាទមានសុពលភាពលើការប្តឹងឧទ្ធរណ៍ជានិច្ច ដោយអគ្គព្រះរាជអាជ្ញាប្តឹងសាទុក្ខនោះ ដោយមានការភាន់ច្រឡំប៉ុណ្ណោះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាបដិសេធបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជ អាជ្ញាសាលាឧទ្ធរណ៍វិញ ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល បានលើកឡើងបន្ថែម នាពេលសវនាការថា: ចំពោះសិទ្ធិរបស់មេធាវីអាចប្តឹងឧទ្ធរណ៍បានក្នុងរឿងនេះ សូមក្រុមប្រឹក្សាជំនុំ ជំរះសំរេច ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់សារណារបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍.ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមហើយ .

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៤០ ចុះថ្ងៃទី២២ ០៥ ២០០៣ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ៩៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា តាមសារណាក្នុងបណ្តឹងសាទុក្ខចុះថ្ងៃទី១០ - ០៩ - ២០០៣ របស់អគ្គព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ លើកឡើងថា សាលក្រមលេខ ៥៧ ចុះថ្ងៃទី០៤ ៣ ១៩៩៤ របស់តុលាការ ក្រុងព្រះសីហនុ បានចូលជាស្ថាពរហើយ ចាប់ពីថ្ងៃដែលសមត្ថកិច្ចនគរបាលចាប់ខ្លួនឈ្មោះហាក់ ផាត កាលពី ថ្ងៃទី១១ ០៥ ១៩៩៩ គឺពេលនោះហើយឈ្មោះ ហាក់ ផាត បានដឹងពីសេចក្តីសំរេចរបស់សាលក្រមរួចហើយ ប៉ុន្តែមេធាវីរបស់ឈ្មោះ ហាក់ ផាត ទើបប្តឹងឧទ្ធរណ៍នៅថ្ងៃទី ២៤ ១០ ២០០២ ឃើញថាហួសកំណត់ពេល ប្តឹងឧទ្ធរណ៍០៣ ឆ្នាំ ហើយពុំអាចប្តឹងឧទ្ធរណ៍បានទៀតទេ ការអះអាងដូចនេះ គឺពុំមានមូលដ្ឋានច្បាស់ លាស់ទេពីព្រោះថា:

. បណ្តឹងឧទ្ធរណ៍ពុំមែនប្តឹងនៅថ្ងៃទី ២៤ ១០ ២០០២ ទេ គឺប្តឹងនៅថ្ងៃទី១៥ ៨ ២០០០ តាមបណ្តឹងឧទ្ធរណ៍លេខ ៦៦ ចុះថ្ងៃទី ២៤ - ១០ - ២០០០ ។

. តុលាការក្រុងព្រះសីហនុ ពុំបានជូនដំណឹងពីសាលក្រមកំបាំងមុខទៅនោះថា ក្រោយពេល ជំនុំជំរះឬ ក៏ក្រោយពេលចាប់ខ្លួនបានក៏ដោយ ។

. នៅពេលចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ ពុំបានធ្វើកំណត់ហេតុស្តីពីការចាប់ខ្លួនទេ ហើយក៏ពុំ មានភស្តុតាងណាថា មុនពេលប្តឹងឧទ្ធរណ៍នៅថ្ងៃទី១៥ ៨ ២០០០ ជនជាប់ចោទ បានទទួលដំណឹងពីសាល ក្រមកំបាំងមុខលេខ ៥៧ ចុះថ្ងៃទី០៤ ០៣ ១៩៩៤ ទេឡើយ ពីព្រោះជនជាប់ចោទបានឆ្លើយថា ពេល

ចាប់ខ្លួន នគរបាលបានប្រាប់ខ្លួនតែពីដីកាចាប់ខ្លួន ដែលដីកានេះព្រះរាជអាជ្ញាបានចេញមុនសាលក្រមកំបាំងមុខទៅទៀត ។ ដូច្នេះក្នុងករណីបែបនេះ តុលាការគប្បីពិចារណាអោយផលប្រយោជន៍ទៅជនជាប់ចោទ ដោយទទួលស្គាល់បណ្តឹងឧទ្ធរណ៍របស់មេធាវីជនជាប់ចោទ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៨ "យ" ចុះថ្ងៃទី២៦ ០៣ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យ សេចក្តីចំពោះមុខជនជាប់ចោទ

១ - ទទួលបណ្តឹងសារទុក្ខលេខ ៤០ ចុះថ្ងៃទី ២២ ០៥ ២០០៣ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៨ "យ" ចុះថ្ងៃទី ២៦ - ០៣ - ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៥ - ១២ - ២០០៤ ។ល៕